# កម្រងឯកសារវិនិយោគវិស័យទេសចរណ៍

## ខែមករា ២០១១

**<insert graphic here>**

## មតិស្វាគមន៍ពី USAID

USAID មានសេចក្តីសោមនស្សរីករាយ បង្ហាញជូនពីកម្រងឯកសារវិនិយោគអំពីឧស្សាហកម្មទេសចរណ៍។

ជាធម្មតានៅក្នុងទីផ្សារដែលកំពុងរីកលូតលាស់ ព័ត៌មានដែលទាក់ទងនឹងការវិនិយោគអាចមានការលំបាកក្នុងការស្វែងរក។ ដូច្នេះគោលបំណងនៃកម្រងឯកសារនេះគឺដើម្បីជួយសំរួលដល់ការប្រមូលទិន្នន័យបឋមមួយចំនួនសំរាប់អ្នកនិងផ្តល់នូវគន្លឹះសំខាន់ៗដែលធ្វើអោយមានការងាយស្រួលក្នុងការប្រមូលព័ត៌មានលំអិតបន្ថែមទៀត។ ឯកសារនេះផ្តល់នូវព័ត៌មានត្រួសៗអំពីនិន្នាការក្នុងការអភិវឌ្ឍនវិស័យទេសចរណ៍និងចង្អុលបង្ហាញពីកត្តាគន្លឹះមួយចំនួនដែល រួមចំណែកធ្វើអោយមានការវិនិយោគប្រកបដោយសុវត្ថិភាព។ ចំនុចសំខាន់ៗដែលត្រូវយកចិត្តទុកដាក់មានដូចជា:

*តើកម្ពុជាមានធនធានទេសចរណ៍សំខាន់ៗអ្វីខ្លះ?*

*តើអ្វីខ្លះជាកត្តាគន្លឹះដែលជំរុញអោយមានតម្រូវការទេសចរណ៍?*

*តើអ្វីខ្លះជាយុទ្ធសាស្រ្តគាំទ្រលើវិស័យទេសចរណ៍របស់រដ្ឋាភិបាល? ហើយតើយុទ្ធសាស្រ្តទាំងនោះគាំទ្រដល់ការអភិវឌ្ឍន៍វិស័យទេសចរណ៍បែបណា?*

*តើស្ថាប័នណាខ្លះដែលចូលរួមសកម្មក្នុងការអភិវឌ្ឍន៍ទេសចរណ៍?*

*តើឱកាសវិនិយោគទេសចរណ៍សំខាន់ៗនៅកន្លែងណាខ្លះ?*

កម្ពុជា ជាប្រទេសដែលមានសេដ្ឋកិច្ចរស់រវើក ដែលទទួលបាននូវការកោតសរសើរយ៉ាងខ្លាំងចំពោះគោលនយោបាយគាំទ្រលើសកម្មភាពវិនិយោគ ។ កម្ពុជាបានបង្ហាញអោយឃើញផងដែរនូវសេដ្ឋកិច្ចដ៏រឹងមាំដែលបានងើបឡើងយ៉ាងឆាប់ពីវិបត្តិហិរញ្ញវត្ថុពិភពលោក ។ ធនាគារ ADB និង IMF បានលើក

កម្ពស់ការព្យាករណ៍ពីកំណើន GDP សំរាប់កម្ពុជាឆ្នាំ ២០១០ ដែលបង្ហាញពីដំណើរសេដ្ឋកិច្ចដ៏រឹងមាំ ។ ទន្ទឹមពេលដែលកម្ពុជាទទួលបានកំណើនសេដ្ឋកិច្ច យ៉ាងឆាប់រហ័សក្នុងអំឡុងទសវត្សរ៍កន្លងមកនេះក៏ដោយក៏នៅតែមានឱកាសវិនិយោគជាច្រើនបន្ថែមទៀតសំរាប់វិនិយោគិន។ យើងសង្ឃឹមថា កម្រងឯកសារវិនិយោគនេះ នឹងជំរុញឲ្យមានសន្ទុះដល់ការវិនិយោគនៅក្នុងឧស្សាហកម្មទេសចរណ៍ និងសូមជូនពរអោយ លោក លោកស្រី ព្រមទាំងអាជីវកម្មរបស់លោក លោកស្រីទទួលបានជោគជ័យ ។

សូមទទួលនូវការគោរពរាប់អានពី គម្រោង
MSME Project, USAID

## ចំណុចខ្លាំងថ្នាក់ជាតិ

ក្នុងកំឡុងមួយទសវត្សរ៍ចុងក្រោយនេះ កម្ពុជាបាន លេចឡើងជាប្រទេសមួយក្នុងតំបន់ដែលដើរតួនាទី យ៉ាងរស់រវើកក្នុងការអភិវឌ្ឍន៍អាជីវកម្មដោយ ជោគជ័យ ព្រមទាំងជំរុញអោយមានកំនើនយ៉ាង ឆាប់រហ័ស ។

## គោលនយោបាយគាំទ្រអាជីវកម្ម

- ✓ ពន្ធអាជីវកម្មទាប- ពន្ធ២០%លើផលចំណេញអាជីវកម្ម (អាចអនុគ្រោះពន្ធរហូតដល់៥ឆ្នាំ ចំពោះការខាតបង់)
- ✓ គ្មានការដាក់កំហិតលើម្ចាស់កម្មសិទ្ធិជាជនបរទេស
- ✓ ចំណាត់ថ្នាក់នាំមុខក្នុងចំណោមប្រទេសចិន ឥណ្ឌា វៀតណាមនិងឥណ្ឌូនេស៊ីចំពោះសេរីភាពសេដ្ឋកិច្ច[១]
- ✓ ប្រព្រឹត្តិស្មើភាពចំពោះវិនិយោគិនទាំងអស់
- ✓ ចំណាត់ថ្នាក់នាំមុខក្នុងចំណោមប្រទេសហ្វីលីពីន ចិន និងវៀតណាមចំពោះការការពារវិនិយោគិន[២]
- ✓ គ្មានការត្រួតពិនិត្យតម្លៃលើទំនិញឬសេវាកម្មជាច្រើនប្រភេទ
- ✓ គ្មានការត្រួតពិនិត្យលើការប្តូររូបិយវត្ថុបរទេសឬ គ្មានការដាក់កំហិតលើការប្តូរប្រាក់ ។
- ✓ គ្មានការដាក់កំហិតលើការបង្វិលដើមទុនទៅប្រទេសវិនិយោគិនវិញ ។
- ✓ ជាប្រទេសដំបូងគេក្នុងចំណោមប្រទេសមានការអភិវឌ្ឍន៍តិច(LDC) ដែលបានចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ។
- ✓ គ្មានការដាក់កំហិតលើបរិមាណពាណិជ្ជកម្ម បន្ថយរបាំងពន្ធគយ ។ កម្ពុជាទទួលបានការ អនុគ្រោះពន្ធគយ និងកូតាទៅកាន់ទីផ្សារធំៗរបស់ពិភពលោក(ដូចជា អាមេរិក អឺរ៉ុប ជប៉ុន និង ប្រទេសជាសមាជិកអាស៊ានជាច្រើនទៀត) ។

អាជ្ញាធរខេត្តមានសិទ្ធិអំណាចក្នុងការអនុម័ត ការវិនិយោគក្រោមទឹកប្រាក់២លានដុល្លារដើម្បីជំរុញការអភិវឌ្ឍន៍អាជីវកម្មឲ្យបានឆាប់រហ័ស

> *"កម្ពុជាកំពុងបើកចំហទាំងស្រុងចំពោះសកម្មភាពអាជីវកម្មហើយរាជរដ្ឋាភិបាលកម្ពុជានឹងខិតខំប្រឹងប្រែងអស់ពីសមត្ថភាពដើម្បីធានាបាននូវបរិយាកាសអនុគ្រោះនិងភាពជោគជ័យសម្រាប់រាល់សហគ្រាសទាំងអស់ នៅកម្ពុជា"* ប្រសាសន៍ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ។

## កម្លាំងពលកម្មមានតម្លៃទាបនិងផលិតភាពខ្ពស់

បើប្រៀបធៀបទៅនឹងដៃគូរប្រកួតប្រជែងជាច្រើន នៅក្នុងតំបន់ប្រទេសកម្ពុជាមានឧត្តមភាពនៃការប្រកួតប្រជែងខ្ពស់លើអត្រាប្រាក់ឈ្នួលនិងកម្លាំងពលកម្មដែលមានផលិតភាពខ្ពស់ដែលធ្វើឲ្យកម្ពុជាក្លាយជាទិសដៅដ៏ទាក់ទាញសម្រាប់ឧស្សាហាកម្មដែលប្រើប្រាស់កម្លាំងពលកម្មច្រើន ។

កាលពីប៉ុន្មានឆ្នាំថ្មីៗកន្លងទៅនេះ កម្លាំងពលកម្មកម្ពុជាបានកើនឡើងជាង៥០% ច្រើនជាងទ្វេរដងនៃអត្រាក្នុងប្រទេសផ្សេងៗរបស់អាស៊ាន[៣]។ដោយមានប្រជាពលរដ្ឋវ័យក្មេងច្រើន(ប្រជាពលរដ្ឋពាក់កណ្តាលមានអាយុក្រោម២០ឆ្នាំ)កម្លាំងពលកម្មនេះនឹងបន្តកើនឡើង ។

> *"កម្ពុជាកំពុងបើកចំហទាំងស្រុងចំពោះសកម្មភាពអាជីវកម្មហើយរាជរដ្ឋាភិបាលកម្ពុជាកំពុងខិតខំព្យាយាមអស់ពីសមត្ថភាពដើម្បីធានាបាននូវបរិយាកាសអនុគ្រោះនិងភាពជោគជ័យសម្រាប់រាល់សហគ្រាសទាំងអស់ នៅកម្ពុជា"* ប្រសាសន៍ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ។

## កម្លាំងពលកម្មមាន តម្លៃទាបនិងមានផលិតភាពខ្ពស់

បើប្រៀបធៀបទៅនឹងដៃគូរប្រកួតប្រជែងជាច្រើននៅក្នុងតំបន់ ប្រទេសកម្ពុជាមានអំណោយផលល្អលើអត្រាប្រាក់ឈ្នួលដែលមានការប្រកួតប្រជែង ហើយកម្លាំងពលកម្មមានផលិតភាពខ្ពស់ធ្វើឲ្យកម្ពុជាក្លាយជាទិសដៅដ៏ទាក់ទាញសម្រាប់ ឧស្សាហកម្មដែលប្រើប្រាស់កម្លាំងពលកម្មច្រើន ។

កាលពីប៉ុន្មានឆ្នាំថ្មីៗកន្លងទៅនេះ កម្លាំងពលកម្មកម្ពុជាបានកើនឡើងជាង៥០% ច្រើនជាងទ្វេរដងនៃអត្រាក្នុងចំណោមប្រទេសអាស៊ានទាំងអស់[៣]។ដោយមានប្រជាពលរដ្ឋវ័យក្មេងច្រើន(ប្រជាពលរដ្ឋពាក់កណ្តាលមានអាយុក្រោម២០ឆ្នាំ)ហើយកម្លាំងពលកម្មនេះនឹងបន្តកើនឡើង ។

*"ដូចនៅប្រទេសចិន និងឥណ្ឌាក្នុងសម័យមុនៗដែរ កម្ពុជាត្រូវបានកំណត់ថា ជាកន្លែងដែលរំពឹងទុកនៅពេលអនាគតសម្រាប់ ការវិនិយោគផ្នែកផលិត ជាពិសេស ដោយសារតែពលកម្មមានតម្លៃទាប និងបុព្វលាភបានិភ័យរបស់ប្រទេសទាប...កម្ពុជាក៏ទទួលបានអត្ថប្រយោជន៍ពីភាពស្ថិតនៅជិតល្មមទៅនឹងឆ្នេរខាងលិចនៃសហរដ្ឋអាមេរិក" ។*

## ទីតាំងយុទ្ធសាស្រ្តក្នុងតំបន់

កម្ពុជាមានទីតាំងអំណោយផលយ៉ាងខ្លាំងដែលស្ថិតនៅចំណុចកណ្តាលតំបន់ដែលមានសកម្មភាពសេដ្ឋកិច្ចខ្លាំងនៅក្នុងពិភពលោក។ដោយស្ថិតនៅជាប់ប្រទេសថៃ និងវៀតណាម កម្ពុជាគឺជាច្រករបៀងសេដ្ឋកិច្ចខាងត្បូង នៃមហាអនុតំបន់ ទន្លេមេគង្គដែលលាតសន្ធឹងពីទីក្រុងហូជីមិញដល់ក្រុងបាងកក ។ ដោយសារតែទីតាំងយុទ្ធសាស្ត្របែបនេះ កម្ពុជាទទួលបានការគាំទ្រគួរអោយកត់សំគាល់ពីសំណាក់ស្ថាប័ណអន្តរជាតិលើការកសាងហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនរបស់ខ្លួនដើម្បីជួយសម្រួលដល់ការធ្វើពាណិជ្ជកម្មនៅក្នុងប្រទេស និងជាមួយប្រទេសជិតខាង។ ជាលទ្ធផលការធ្វើពាណិជ្ជកម្មជាមួយនឹងប្រទេសវៀតណាម និងថៃ កំពុងរីកចម្រើនយ៉ាងឆាប់រហ័ស ។




*"អ្នកមានទីក្រុងធំៗបំផុតពីរ នៅអាស៊ីអមសងខាងអ្នក ។ អ្នកមានប្រជាជន១៥លាននាក់នៅទីក្រុងបាងកក និង៨លាននាក់នៅទីក្រុង ហូជីមិញហើយអ្វីផ្សេងៗទៀតនឹងកើតមានកាន់តែច្រើនឡើងៗ ចន្លោះទីក្រុងទាំងពីរ" ។ Edward Hopkins, CB Richard Ellis Group Inc.*

# ហេតុផលក្នុងការធ្វើវិនិយោគលើវិស័យទេសចរណ៍នៅកម្ពុជា

### ១. សេចក្តីផ្តើម

ទោះបីមានទំហំដីតូច កម្ពុជាមានធនធានទេសចរណ៍ដ៏ច្រើនក្រៃលែងដែលផ្តល់លទ្ធភាពឲ្យវិស័យនេះអាចឆ្លើយតបតាមតម្រូវការទីផ្សារសក្តានុពលនានាបាន។ទាំងនេះគឺគិតរួមទាំងការទាក់ទាញដែលមានការទទួលស្គាល់ជាលក្ខណៈអន្តរជាតិតាមរយៈ UNESCO ដូចជាតំបន់រមណីយដ្ឋានបេតិកភណ្ឌពិភពលោក អង្គរវត្ត និង ប្រាសាទព្រះវិហារ ដែនបបនីយជីវមណ្ឌលទន្លេសាបនិងតំបន់ឆ្នេរដែលមានឆ្នេរល្អបំផុត[៤]នៅអាស៊ី ។

គុណសម្បត្តិនៃធនធានទាំងនេះបង្ហាញនៅក្នុងអត្រាកំណើនក្នុងឧស្សាហកម្មទេសចរណ៍។

កម្ពុជាត្រូវបានចាត់ចំណាត់ថ្នាក់លេខមួយនៅក្នុងចំណោមប្រទេស១៨១ចំពោះអត្រាកំណើនពិតប្រាកដនៅក្នុង ការធ្វើដំណើរ និងដំណើរកំសាន្តផ្ទាល់ខ្លួន[៥] ។

តែទោះជាបែបនេះក៏ដោយ កម្ពុជាទទួលបានតែ ៣,៣%នៃការមកដល់របស់ភ្ញៀវទេសចរសរុបនៅក្នុងតំបន់អាស៊ាន។ លើសពីនេះទៅទៀត ការស្នាក់នៅជាមធ្យម នៅកម្ពុជា គឺមានត្រឹមតែ៦,៤៥ ថ្ងៃប៉ុណ្ណោះហើយមានកំនើនខ្ពស់ខ្លាំងនៅតែតំបន់អង្គរខេត្តសៀមរាប[៦] ។

ក្រៅពីកំណើនផ្នែកប្រវត្តិសាស្ត្រនៅមានសក្តានុពលសំខាន់ផ្សេងៗទៀតនៅក្នុងវិស័យនេះដែលអាចផ្តល់កាលានុវត្តន៍ភាពលើការវិនិយោគជាច្រើន ។ ជាការឆ្លុះបញ្ចាំងពីស្ថានភាពវិជ្ជមាននៃវិស័យទេសចរណ៍បច្ចុប្បន្ន និងអនាគតកំណើនឧស្សាហកម្មកម្ពុជាត្រូវបានទទួលស្គាល់និងផ្តល់រង្វាន់ពីទស្សនាវដ្តីForbes.com កាសែត*The Guardian*[៧] និង Lonely Planet[៨]។

## ២. ធនធាន

កម្ពុជាមានធនធានទេសចរណ៍ថ្នាក់ពិភពលោកសំបូរបែបដែលអាចទាក់ទាញទេសចរបានយ៉ាងច្រើន ដែលក្នុងនោះរួមមានធនធានវប្បធម៌ប្រវត្តសាស្ត្រ និងធនធានធម្មជាតិជាច្រើន។

## វប្បធម៌ និងប្រវត្តិសាស្ត្រ

ព្រះរាជាណាចក្រកម្ពុជា ស្ថិតនៅចំកណ្តាលនៃអាណាចក្រមួយក្នុងចំណោមអាណាចក្រដ៏មានឥទ្ធិពលបំផុតដែលគ្រប់គ្រងនៅអាស៊ីអាគ្នេយ៍។ អាណាចក្រខ្មែរនៅក្នុងសម័យដ៏រុងរឿងពីសតវត្សរ៍ទី៩ដល់ ទី១៣ ដែលគ្រប់គ្រងលើ ប្រទេសឡាវ ថៃ វៀតណាម ភូមា និងឧបទ្វីបម៉ាឡេនាសម័យបច្ចុប្បន្ន ។ តំបន់រមណីយដ្ឋានបេតិកភណ្ឌពិភពលោកដែលកំណត់ដោយ UNESCO អង្គរវត្ត ដែលស្ថិតនៅក្នុងខេត្តសៀមរាបត្រូវបានចាត់ទុកជាកេរ្តិ៍ដំណែលដ៏ធំធេងបំផុត ។

មានប្រាសាទបុរាណជាង១០០០នៅទូទាំងប្រទេសកម្ពុជា។នៅក្នុងចំណោមប្រាសាទទាំងនោះ ប្រាសាទព្រះវិហារគឺជារមណីយដ្ឋានបេតិភណ្ឌពិភពលោកទី២ដែលកំណត់ដោយ UNESCO ។

ការទាក់ទាញប្រាសាទអង្គរវត្តដែលបង្ហាញតាមការសិក្សាស្ទង់មតិថ្មីៗនៅលើគេហទំព័រអ៊ិន ធឺណេតTrip Advisor.com អំពី ការធ្វើដំណើរទេសចរណ៍ដែលទទួលបានចំណាត់ថ្នាក់ពិភពលោកលេខ១ដែលជារមណីយដ្ឋាន UNESCO បានស្នើឲ្យចូលមកទស្សនាច្រើនបំផុត។ ការទាក់ទាញនេះជំរុញតម្រូវការនៅគ្រប់ផ្នែកទាំងអស់នៃភ្ញៀវទេសចរ។ ដោយយោងតាមទស្សនាវដ្តីទេសចរណ៍ដែលលក់ដាច់ជាងគេបំផុតបានបង្ហាញថាខេត្តសៀមរាបមានសណ្ឋាគារ៣ក្នុងចំណោមសណ្ឋាគារដែលល្អជាងគេចំនួន ហើយសរុបមានចំនួន៤ ដោយគិតបញ្ចូលទាំងសណ្ឋាគារមួយទៀតនៅទីក្រុងភ្នំពេញ ប្រៀបធៀបជាមួយនឹងចំនួនសរុបនៅប្រទេសជិតខាង វៀតណាមចំនួន(២) ម៉ាឡេស៊ី(៤) ឥណ្ឌូនេស៊ី(២) និងហ្វីលីពីន (២) ។

### អេកូទេសចរណ៍





ស្ថិតក្នុងចំណោមតំបន់ភូមិសាស្ត្រចម្រុះដែលមានអំណោយផលពីប្រព័ន្ធអេកូឡូស៊ីកម្ពុជា គឺជាលំនៅដ្ឋានមួយសំរាប់ជម្រកធម្មជាតិដែលសំបូររុក្ខជាតិ និងសត្វជាច្រើនប្រភេទ។

បេះដូងកម្ពុជាគឺអាងទន្លេសាប និងវាលទំនាបទន្លេមេគង្គដែលជាផ្ទៃបឹងទឹកសាបដ៏ធំល្វឹងល្វើយនៅក្នុងតំបន់និងជាចំណុចកណ្តាលដែនបបនីយជីវមណ្ឌលទន្លេសាបកណត់ដោយ UNESCO ។ ផ្នែកនិរតីគឺដីសណ្តរទន្លេមេគង្គ ដែលលាតសន្ធឹងដល់ប្រទេសវៀតណាម ដែលធ្វើឲ្យងាយស្រួលដល់ការដឹកជញ្ជូនតាមផ្លូវទឹករវាងប្រទេសទាំងពីរ ។ អាងនិងតំបន់ដីសណ្តរទាំងនេះព័ទ្ធជុំ វិញដោយជួរភ្នំ។ នៅភាគនិរតីមានទស្សនីយភាពគួរឲ្យចាប់អារម្មណ៍ដែលលាតសន្ធឹងរហូតដល់ឆ្នេរសមុទ្រខាងត្បូងគឺតំបន់ជួរភ្នំក្រវ៉ាញនិងភ្នំដំរី។ នៅភាគខាងជើងនៃប្រទេសគឺជួរភ្នំដងរែក ហើយនៅភាគឦសាន គឺខេត្តរតនគិរី និងមណ្ឌលគិរីដែលរួមបញ្ចូលទៅក្នុងតំបន់ខ្ពង់រាបកណ្តាលនៃប្រទេសវៀតណាម ។

ប្រភេទថនិកសត្វ ល្មូន ត្រីទឹកសាប និងត្រីទឹក ប្រៃត្រូវបានគេឃើញមាននៅពាសពេញផ្ទៃប្រទេស។ ប្រភេទភាគច្រើននៃសត្វទាំងនេះបានទទួលស្គាល់ដោយអង្គការអភិរក្សធម្មជាតិអន្តរជាតិ (IUCN) ថាជាប្រភេទសត្វដែលកំពុងទទួលរងការគំរាមកំហែងងាយរងគ្រោះ ឬប្រភេទសត្វជិតផុតពូជ ដោយរួមទាំងសត្វផ្សោតទន្លេមេគង្គ (Irrawaddy Dolphin) ផង។

ដើម្បីអភិរក្សនូវជីវចម្រុះទាំងនេះរដ្ឋាភិបាលបានកំនត់ឲ្យមានតំបន់ការពារប្រហែល ២៥% នៃផ្ទៃប្រទេសទាំងមូល ។ តំបន់ទាំងនេះរួមមានឧទ្យានជាតិចំនួន៧ ដែនជម្រកសត្វព្រៃចំនួន១០ តំបន់ការពារទេសភាពចំនួន៣ តំបន់ប្រើប្រាស់ច្រើនយ៉ាងចំនួន៣ និងព្រៃការពារ[៩]ចំនួន ៩។

## តំបន់ឆ្នេរ

ការផ្តោតសំខាន់មួយទៀតរបស់ទេសចរណ៍ គឺឆ្នេរសមុទ្រកម្ពុជាដែលមានប្រវែង៤៤០គមនៅឈូងសមុទ្រថៃ។

តំបន់នេះមានតំបន់គោលដៅលំហែកាយឆ្នេរ កំពតកែប កោះកុង និងព្រះសីហនុ ដែលស្ថិត នៅប៉ែកនិរតីនៃរាជធានីភ្នំពេញ ។ ក្រៅពីតំបន់ទាំងនេះមានតំបន់ប្រជុំកោះចំនួន២២ដែលមានចំងាយមិនឆ្ងាយពីឆ្នេរប៉ុន្មានទេ ។ នៅឆ្នាំ២០១០ទស្សនាវដ្តី Forbes.comបានចុះឆ្នេរអូត្រេះ ឆ្នេរកោះរុង និងឆ្នេររាមដែលនៅក្បែរ ក្រុងព្រះសីហនុក្នុងបញ្ជីឆ្នេរសមុទ្រល្អបំផុតនៅអាស៊ី ។

### ៣. ស្ថានភាពទីផ្សារ[១០]

នៅឆ្នាំ ២០០៩ កម្ពុជាបានទាក់ទាញភ្ញៀវទេសចរចំនួន ២,១៦លាននាក់ ដែលបង្ហាញពីការកើនឡើងលើសឆ្នាំ ២០០៨ ចំនួន ១,៧%។ ដោយសារឥទ្ធិពលវិបត្តិហិរញ្ញវត្ថុពិភពលោក ចំនួនភ្ញៀវទេសចរមកពីប្រទេសនានាភាគច្រើនបានធ្លាក់ចុះប៉ុន្តែត្រូវបានជំនួសមកវិញដោយសារមានកំណើនលើសលុបផ្នែកទេសចរណ៍ពីទីផ្សារធំៗ ដូចជាចក្រភពអង់គ្លេស (ទីផ្សារធំទី៦) បារាំង(ទីផ្សារធំទី៧) និងជាពិសេស វៀតណាម (ទីផ្សាធំទី១)។

ចំពោះរយៈពេល៧ខែដំបូងនៃឆ្នាំ ២០១០ ក្រសួងទេសចរណ៍បានរាយការណ៍អំពីកំណើនប្រចាំឆ្នាំប្រមាណជា១៣,៨% ។ នេះបង្ហាញនូវការងើបឡើងដែលគួរអោយកត់សំគាល់ក្នុងវិស័យទេសចរណ៍នៅពីប្រទេសអាស៊ី ដែលមានកំនើនសេដ្ឋកិច្ចល្អឡើងវិញ ។

ការមកដល់ភ្ញៀវទេសចរនៅកម្ពុជាបានជិះឥទ្ធិពលពីកំនើនទេសចរណ៍សរុប(៨៥% ឆ្នាំ២០០៩)។ ដោយសារមានលក្ខណៈអំណោយផលពីអាកាសធាតុកម្ពុជាជាគោលដៅដែលមានការពេញនិយមនៅពេញមួយឆ្នាំ ។ ផ្អែកលើការមកដល់ភ្ញៀវទេសចរនៅចំណតអាកាសយានដ្ឋានខេត្តសៀមរាប បំរែបំរួលនៃការថយចុះឬការកើនឡើយជាមធ្យមមានតំលៃចន្លោះ៣០% ដូចដែលមានបង្ហាញនៅក្នុងក្រាហ្វិកខាងក្រោម ។

**ការមកដល់ភ្ញៀវទេសចរនៅចំណតអាកាសខេត្តសៀមរាប(២០០៩)**



ភ្ញៀវទេសចរចែកជាពីរស្មើគ្នា គឺភ្ញៀវមកជាក្រុម និងភ្ញៀវមកជាលក្ខណៈឯកជន ទោះជាយ៉ាងណា ភ្ញៀវក្រុមត្រូវបានគេសំគាល់ថាមានការចំណាយច្រើនជាងភ្ញៀវឯកជន ។

### ការចំណាយសរុបតាមប្រភេទភ្ញៀវទេសចរ(២០០៩)

| | %ភ្ញៀវទេសចរ | ចំណាយជាមធ្យម |
|---|---|---|
| ភ្ញៀវក្រុម | ៥០% | $ ១.១៣៥,៩៣ |
| ភ្ញៀវឯកជន | ៥០% | $ ៤២៥,៦៧ |

ភ្ញៀវទេសចរចំណាយជាមធ្យមគឺ UD$ ១១៧,២៥ក្នុងមួយថ្ងៃ។

## ទេសចរណ៍ឆ្លងតំបន់

ភ្ញៀវទេសចរជាច្រើនដែលមកដល់កម្ពុជាគឺឆ្លងកាត់តាមតំបន់ ដែលត្រូវឈប់សំរាកជាច្រើនប្រទេសនៅក្នុងតំបន់អាស៊ាន ឬមហាអនុតំបន់ទន្លេមេគង្គ។ ដូចនេះប្រជាប្រិយភាពចេះតែកើនឡើងជាដែលជំរុញបន្ថែមដល់ឧស្សាហកម្មទេសចរណ៍កម្ពុជា។ រយៈពេលចន្លោះពី២០០៥-២០១០កំណើនមកដល់ក្នុងតំបន់ជាមធ្យម១៦%ប្រចាំឆ្នាំ[១១]ដែលមានភ្ញៀវទេសចរឡើងលើសពី២៤លាននាក់នៅក្នុងឆ្នាំ២០០៩ ។

កត្តាជំរុញកំនើននេះគឺបណ្តាលមកពីការតភ្ជាប់បណ្តាញប្រព័ន្ធគមនាគមន៍ក្នុងតំបន់ដែលជាគោលបំណងដ៏ ធំនៃការចូលរួមរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍មហាអនុតំបន់ទន្លេមេគង្គ ។

## តម្រូវការក្នុងស្រុក និងអាស៊ាន

កម្ពុជានៅចន្លោះឆ្នាំ១៩៩៧ដល់២០០៧បានសម្រេចនូវអត្រាកំណើនសេដ្ឋកិច្ចយ៉ាងខ្ពស់គួរឲ្យកត់សំគាល់ដែលជាមធ្យមគឺ៩,៨%។ ប្រាក់ចំណូលប្រជាជនម្នាក់ៗ កើនឡើងទ្វេដងពី USD ២៨៥ក្នុងឆ្នាំ១៩៩៧ដល់ USD ៧៣៩ ក្នុងឆ្នាំ ២០០៨[១២] ។ កំណើននេះបណ្តាលមកពីការកើនឡើងទេសចរណ៍ក្នុងស្រុក ។ នៅឆ្នាំ២០០៩ ភ្ញៀវទេសចរជាតិជាង៧លាននាក់បានធ្វើដំណើរទស្សនានៅតាមតំបន់ទេសចរណ៍នានាក្នុងប្រទេសកម្ពុជា[១៣] ។

ស្រដៀងគ្នានេះដែរ ដំណើរការសេដ្ឋកិច្ចដ៏រឹងមាំនៃតំបន់អាស៊ីប៉ាស៊ីហ្វិកជាកត្តាជំរុញអោយមានតម្រូវការទេសចរណ៍កាន់តែខ្លាំងថែមទៀតដែលកម្ពុជាជាអ្នកទទួលផលមួយយ៉ាងច្រើន។

### ភ្ញៀវទេសចរមកដល់កម្ពុជាតាមតំបន់ (២០០៩)[១៤]

| ប្រភពដើម | |
|---|---|
| អាស៊ីប៉ាស៊ីហ្វិក | ៦៩% |
| អឺរ៉ុប | ២២% |
| អាមេរិក | ៩% |

ក្នុងចំណោម៦៩% មកពីអាស៊ីប៉ាស៊ីហ្វិក ៣៤% នៃភ្ញៀវទេសចរសរុបគឺមកពីបណ្តាប្រទេសអាស៊ាន។

## ឧបសគ្គក្នុងការផ្គត់ផ្គង់

នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៩-២០១៣[១៥] រាជរដ្ឋាភិបាលកម្ពុជាបានកំណត់នូវបញ្ហាជាច្រើនដែលរាំងដល់ការអភិវឌ្ឍន៍វិស័យទេសចរណ៍ ។ នៅក្នុងចំណោមបញ្ហាទាំងនេះមានដូចជាតំលៃខ្ពស់នៃកញ្ចប់ទេសចរណ៍ ជាពិសេសនៅពេលធ្វើការប្រៀបធៀបទៅនឹងប្រាក់ចំណូលម្នាក់ៗ។ បញ្ហានេះបណ្តាលមកពីខ្វះការប្រកួតប្រជែងនៅក្នុងទីផ្សារសំរាប់សេវាកម្មទេសចរណ៍និងខ្វះកម្លាំងពលកម្មជំនាញសមស្រប។
ដោយសារតែជាសេវាកម្មឧស្សាហកម្មប្រើកម្លាំងពលកម្មច្រើនវិស័យទេសចរណ៍តម្រូវអោយមាននិយោជិតដែលមានគុណសម្បត្តិសមស្របនិងមានកំរិតជំនាញច្បាស់លាស់ពិសេសជាច្រើនផ្នែក។ កម្ពុជាមានកម្លាំងពលកម្មវ័យក្មេងច្រើនដែលមានប្រសិទ្ធភាពខ្ពស់បើប្រៀបធៀបជាមួយមជ្ឈដ្ឋានអន្តរជាតិ។ តែទោះជាយ៉ាងណាក៏ដោយកំលាំងពលកម្មដែលសមស្របក្នុងវិស័យនេះមានចំនួនតិចតួចនៅឡើយហើយកាន់តែមានកំរិតទៅ

ទៀតក្រៅពីក្រុងភ្នំពេញនិងខេត្តសៀមរាប។ស្ថិតនៅក្នុងស្ថានភាពបែបនេះគឺមានការចំណាយខ្ពស់លើការ

បណ្តុះបណ្តាលដើម្បីទទួលបានបុគ្គលិកល្អហើយ បញ្ហានេះត្រូវមានការរួមចំនែកយ៉ាងច្រើនពី សហគ្រាសធុនតូចនិងធុនមធ្យម ដែលផ្តល់សេវាច្រើនក្នុងការជំរុញអោយមានការលូតលាស់ក្នុងវិស័យទេសចរណ៍។

លើសពីនេះទៅទៀត ការអភិវឌ្ឍន៍ទេសចរណ៍នៅកម្ពុជាមកដល់បច្ចុប្បន្នមានទំនោរទៅរកតំបន់ទីក្រុង ហើយមានការខ្វះខាតច្រើននៅក្នុងតំបន់ផ្សេងៗទៀត ។
នេះបានជិះឥទ្ធិពលអោយមានការអភិវឌ្ឍន៍អេកូទេសចរណ៍កាន់តែច្រើនឡើងៗ ។

## ៤.ការលើកកម្ពស់បរិយាកាសអាជីវកម្ម




ចំនូលសរុបក្នុងវិស័យទេសចរណ៍ឆ្នាំ២០០៩មានចំនួន១,៦ពាន់លានដុល្លាដែលចំនួននេះបានចូលរួមចំនែកប្រហែល១៩%នៃផលិតផលក្នុងស្រុកសរុប ។ ដូចនេះក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាបានចាត់ថ្នាក់ទេសចរណ៍ជាវិស័យមួយក្នុងចំណោមវិស័យអាទិភាពសំរាប់ការវិនិយោគបរទេស ។

## គោលនយោបាយគាំទ្រ

គោលនយោបាយរដ្ឋាភិបាលសំរាប់វិស័យទេសចរណ៍ដែលរៀបរាប់នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០០៩-២០១៣ដែលរៀបចំសកម្មភាពថ្មីៗនិងអាទិភាពអភិវឌ្ឍន៍សំខាន់ៗ។
សមិទ្ធផលទាំងនេះ រួមមាន:

- សម្រួលលើតម្រូវការទិដ្ឋាការ រួមទាំងការបដិសេដ្ធទិដ្ឋាការ ការផ្តល់ទិដ្ឋាការពេលមកដល់ និងការ ដាក់សុំទិដ្ឋាការតាមប្រព័ន្ធអ៊ិនធឺណេត
- គោលនយោបាយបើកចំហាជើងមេឃដើម្បីលើកទឹក ចិត្តដល់ចរាចរណ៍អាកាសមកកម្ពុជា និងនៅក្នុងកម្ពុជា ។
- កម្មវិធី "ទីក្រុងស្អាត រមណីយដ្ឋានស្អាត និងសេវាល្អ"ដើម្បីលើកកំពស់កំរិតសេវាកម្មនៅតំបន់គោលដៅទេសចរណ៍សំខាន់ៗ ។
- ការកសាងចំណតអាកាសយានដ្ឋានអន្តរជាតិថ្មីនៅខេត្តព្រះ សីហានុនៅឆ្នេរសមុទ្រខាងត្បូង ។

រដ្ឋាភិបាលក៏កំពុងស្វែងរកដៃគូយ៉ាងសកម្មផងដែរដើម្បីសហការលើការអភិវឌ្ឍន៍និងបណ្តុះបណ្តាលជំនាញ ដូចដែលបានបង្ហាញតាមការព្រមព្រៀងថ្មីៗជាមួយនឹងសាកលវិទ្យាល័យ Sunshine Coast, ប្រទេសអូស្ត្រាលី ។

## ការផ្សព្វផ្សាយ



រដ្ឋាភិបាលបានធ្វើការងារយ៉ាងយកចិត្តទុកដាក់ដើម្បីផ្សព្វផ្សាយកេរ្តិ៍ឈ្មោះកម្ពុជា និងសក្តានុពលទេសចរណ៍។ ក្រសួងទេសចរណ៍ បានបើកយុទ្ធនាការផ្សព្វផ្សាយពាណិជ្ជកម្ម "ព្រះរាជាណាចក្រអច្ឆរិយៈ" តាមប្រព័ន្ធផ្សព្វផ្សាយអន្តរជាតិ ដូចជា CNN និងប្តេជ្ញានាំយកមកនូវព្រឹត្តិការណ៍អន្តរជាតិធំៗចូលមកក្នុងប្រទេស។ កម្ពុជានឹងធ្វើជាម្ចាស់ផ្ទះវេទិកាទេសចរណ៍អាស៊ានលើកទី៣០នៅឆ្នាំ២០១១ និងកំពុងធ្វើការងារឆ្ពោះទៅការការធ្វើជាម្ចាស់ផ្ទះស៊ីហ្គេម ២០១៥ ។

## សហប្រតិបត្តិការអន្តរជាតិ

រាជរដ្ឋាភិបាលកម្ពុជាជាអ្នកចូលរួមដ៏សកម្មនៅក្នុងយុទ្ធសាស្ត្រវិស័យទេសចរណ៍មហាអនុតំបន់ទន្លេមេគង្គ ដែលមានអត្ថិភាពដើម្បីអភិវឌ្ឍន៍និងជំរុញ

តំបន់ឲ្យទៅជា តំបន់គោលដៅទេសចរណ៍តែមួយ ។ អនុវត្តដោយរដ្ឋាភិបាលប្រទេសជាសមាជិក ចំនួន៦ (កម្ពុជា ឡាវ ភូមា ថៃ វៀតណាម ហើយនិងខេត្តយូណាន និងខេត្តខាងស៊ីនៅប្រទេសចិន) និងទទួលបានការគាំទ្រដោយ ធនាគារអភិវឌ្ឍន៍អាស៊ី និងអង្គការពហុភាគីផ្សេងៗទៀតដោយមានការប៉ាន់ស្មានថវិកា អនុវត្តប្រហែលចំនួនUSD ៨៤១លាន ដែលចំនួនUSD ៣៧៣លានសំរាប់ហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍[១៧] ។

កម្ពុជាស្ថិតនៅក្នុងតំបន់៦ក្នុងចំណោមអនុតំបន់អាទិភាព១៣ ដែលជាគោលដៅសំរាប់អភិវឌ្ឍន៍ទេសចរណ៍: តំបន់ត្រីកោណមរកត តំបន់ត្រីកោណអភិវឌ្ឍន៍បៃតង ច្រករបៀងឆ្នេរសមុទ្រទេសចរណ៍ខាងត្បូង ខ្សែបន្ទាត់ឆ្នេរសមុទ្រ និងទន្លេមហាអនុតំបន់ទន្លេមេគង្គ ខ្សែទស្សនាតំបន់បេតិកភណ្ឌពិភពលោក និងច្រករបៀងទេសចរណ៍ទន្លេមេគង្គ ។

## ការពិភាក្សារវាងរដ្ឋ-ផ្នែកឯកជន

អាជីវកម្មទេសចរណ៍ផ្សាភ្ជាប់ជាមួយនឹងស្ថាប័នរដ្ឋ នៅក្នុងគោលនយោបាយអភិវឌ្ឍន៍ទេសចរណ៍តាមរយៈក្រុមការងារទេសចរណ៍ ដែលពួកគេអាចកំណត់នូវបញ្ហាការប្រឈមនិងផ្តល់អនុសាសន៍សំរាប់ដំណោះស្រាយដល់ រដ្ឋាភិបាល ។

## ការលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុ

**គម្រោងវិនិយោគលក្ខណៈសម្បត្តិគ្រប់គ្រាន់(QIPs)**
ទទួលបានការអនុម័តដោយ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា(CDC) ដោយមានការលើកទឹកចិត្តហិរញ្ញវត្ថុមួយចំនួន ថែមទាំងការលើកលែងពន្ធថ្ងៃឈប់សំរាក និងការរួចពន្ធនាំចូលសំរាប់ឧបករណ៍ផលិត និងសំភារៈសំណង់ ។ QIPs មិនចាំបាច់តម្រូវអោយធ្វើការបង់ពន្ធប្រាក់ចំណេញ និងដាក់ពន្ធអប្បបរមានៅអំឡុងពេលរួចពន្ធ ។ ខាងក្រោមគឺជានិតិវិធីសំរាប់ការដាក់ពាក្យសុំQIPs នៅក្នុងវិស័យទេសចរណ៍:

- សណ្ឋាគារលំដាប់ថ្នាក់ផ្កាយបីនិងលើផ្កាយបី
- បរិវេណទេសចរណ៍ជាសណ្ឋាគារដែលមានជាង១០០បន្ទប់និងមណ្ឌលកំសាន្តមានសេវាចម្រុះដែលមានទំហំលើសពី១០ហិកតា
- ទេសចរណ៍ធម្មជាតិ និងការបង្កើតតំបន់ទេសចរណ៍ធម្មជាតិដែលមានទំហំពី១០០០ហិកតា និងដើមទុនវិនិយោគចាប់ពី១លានដុល្លារ ។
- បរិវេណមណ្ឌលកំសាន្ត មាន សណ្ឋាគារ ឧទ្យាន សំភារៈហាត់កីឡា ឬសួនសត្វដែលមានទំហំចាប់ពី៥០ហិកតា ។

ការវិនិយោគទុនក្រោមទឹកប្រាក់ ២លានដុល្លារ គឺត្រូវអនុម័តដោយអាជ្ញាធខេត្តដោយមិនចាំបាច់ការអនុម័តយល់ព្រមពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា(CDC) នៅភ្នំពេញឡើយ ។ ខេត្តនីមួយៗ មាន អនុគណៈម្មាធិការវិនិយោគខេត្តសំរាប់គោលបំណងនេះ ដែលមានអភិបាលខេត្តជាប្រធាននិងជាតំណាងតំបន់របស់CDC។កន្លែងណាដែលអនុគណៈកម្មាធិការមិនទាន់ដំណើរការពេញលេញវិនិយោគិនអាចដំណើរការតាមរយៈ CDC នៅភ្នំពេញ ។

### សេវាហិរញ្ញវត្ថុ

កម្ពុជាមានវិស័យហិរញ្ញវត្ថុរីកចម្រើន ដែលមានធនាគារ៣៣ និងស្ថាប័នមីក្រូហិរញ្ញវត្ថុ២០ ដែលផ្តល់អាជ្ញាប័ណ្ណដោយធនាគារជាតិនៃ កម្ពុជា ។ ជារួមស្ថាប័នហិរញ្ញវត្ថុទាំងនេះផ្តល់ប្រាក់កម្ចីជាង៣០០០លានដុល្លារអាមេរិកក្នុងឆ្នាំ២០០៩។ធនាគារតាមប្រព័ន្ធអ៊ិនធឺណេត ធនាគារតាមប្រព័ន្ធទូរស័ព្ទ និង ATMs មាននៅតាមទីក្រុង និងទីប្រជុំជននានាជាច្រើន ។ ដើម្បីជំរុញអោយកាន់តែមានគុណភាពក្នុងវិស័យនេះ ធនាគារជាតិនៃកម្ពុជា បានតម្រូវឲ្យ ធនាគារពាណិជ្ជកម្មនីមួយៗបង្កើនដើមទុនតម្កល់បីដងដែលមានតំលៃប្រហែល ៣៧លាន[១៨]ដុល្លារអាមេរិក ។

### ៥. ហេដ្ឋារចនាសម្ព័ន្ធគាំទ្រ

បរិមាណស្រដៀងគ្នានៃភ្ញៀវទេសចរមកដល់ កម្ពុជាតាមផ្លូវគោក ផ្លូវទឹក និងផ្លូវអាកាស ។ នេះបង្ហាញពីទីតាំងសំខាន់របស់កម្ពុជា និងលក្ខណៈទេសចរណ៍ឆ្លងដែន ។

ភាគរយនៃភ្ញៀវទេសចរដែលមកដល់តាមមធ្យោបាយនានា (២០០៩)[១៩]

| មធ្យោបាយមកដល់ | % |
| --- | --- |
| ចំណាតអាកាសអន្តរជាតិភ្នំពេញ | ២៤ |
| ចំណាតអាកាសអន្តរជាតិសៀមរាប | ២៧ |
| ផ្លូវគោក | ៤០ |
| ផ្លូវទឹក | ៤ |
| ឆ្លងកាត់[២០] | ៥ |

ដើម្បីសម្រួលដល់ការធ្វើដំណើរមកកម្ពុជា និងនៅក្នុងកម្ពុជា រដ្ឋាភិបាលបានវិនិយោគយ៉ាងច្រើនលើហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ។

## ផ្លូវថ្នល់

កម្ពុជាបានលើកកម្ពស់ប្រព័ន្ធផ្លូវថ្នល់របស់ខ្លួន និងស្ពានឆ្លងកាត់ជាច្រើន។ មានច្រកព្រំដែនអន្តរជាតិតាមផ្លូវគោក៧ហើយកម្ពុជាមានច្រកចេញចូលងាយស្រួលទៅមកជាមួយប្រទេសជិតខាងដូចជាថៃ ឡាវ និងវៀតណាម ។

## ផ្លូវអាកាស

មានច្រកអន្តរជាតិធំៗពីរចំពោះការមកដល់តាមផ្លូវអាកាស គឺចំណាតអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ និងចំណាតអាកាសយានដ្ឋានអន្តរជាតិសៀមរាប ។ រដ្ឋាភិបាលមាន ចំណាប់អារម្មណ៍ពង្រីកផ្លូវមួយចំនួន និងទើបបានចុះហត្ថលេខាថ្មីៗលើកិច្ចព្រមព្រៀងសំរាប់ការហោះត្រង់ ផ្ទាល់ពីទីក្រុង ហ្សាកាតា មកកាន់រាជធានីភ្នំពេញនិង ពី បាលី មកកាន់ ខេត្តសៀមរាប ។ ចំណាតអាកាសយានដ្ឋានអន្តរជាតិទីបីដែលបានសាងសង់ឡើងនៅក្បែរក្រុង ព្រះសីហនុនៅឆ្នេរសមុទ្រខាងត្បូង តែនៅមិនទាន់បានដាក់អោយដំណើរការនៅឡើយទេ ។

## ផ្លូវដែក

បណ្តាញផ្លូវដែកកម្ពុជាដែលជាផ្នែកនៃគំរោងផ្លូវដែលឆ្លងកាត់អាស៊ីកំពុងត្រូវបានសាងសង់ឡើងវិញ។ ផ្លូវដែកនេះមានពីរខ្សែៈ ផ្លូវទីមួយចន្លោះពី ភ្នំពេញ ទៅប៉ោយប៉ែត(ឆ្លងកាត់ផ្លូវគោកដ៏សំខាន់ទៅកាន់ប្រទេសថៃភាគខាងលិច) និងផ្លូវទី២ រវាង ភ្នំពេញ ជាមួយនឹង ខេត្តព្រះសីហនុ។ ផ្លូវទីបីតភ្ជាប់ពីភ្នំពេញទៅប្រទេសវៀតណាមត្រូវបានគេរៀបចំគម្រោងហើយ ផងដែរ ។

## ផ្លូវទឹក

កម្ពុជាមានផ្លូវទឹកជាច្រើនដែលរួមមានទន្លេមេគង្គ ទន្លេសាប និងដៃទន្លេជាច្រើនទៀត។ ផ្លូវទឹកទាំងនេះដើរតួនាទីយ៉ាងសំខាន់លើវិស័យទេសចរណ៍ និងការដឹកជញ្ជូន។ លើសពីនេះទៅទៀត ឆ្នេរសមុទ្រភាគខាងត្បូងនៃកំពង់ផែសមុទ្រអន្តរជាតិខេត្តព្រះសីហនុបានទទួលនាវាកំសាន្តជាច្រើនដែលធ្វើដំណើរឆ្លងកាត់ឈូងសមុទ្រថៃ ។

## កាលានុវត្តន៍ភាពវិនិយោគ

ការពិភាក្សាអំពីការអភិវឌ្ឍន៍ទេសចរណ៍នៅកម្ពុជាជារឿយៗតម្រង់គោលដៅទៅរកតំបន់សៀមរាប ភ្នំពេញ តំបន់ភាគឦសាន និងប៉ែកអាគ្នេយ៍។ តំបន់នីមួយៗមានលក្ខណៈភូមិសាស្ត្រពិសេសរៀងៗខ្លួន ព្រមទាំងមានសក្តានុពលសេដ្ឋកិច្ចនិងទេសចរណ៍ផ្សេងៗពីគ្នា។ ក្រាហ្វិកខាងក្រោមបង្ហាញពីទីតាំងតំបន់ទាំងនេះ។

### សៀមរាប តំបន់ឦសាន ឆ្នេរសមុទ្រខាងត្បូងនិងភ្នំពេញ




តារាងខាងក្រោមបង្ហាញពីភាគរយនៃភ្ញៀវទេសចរអន្តរជាតិទៅកាន់តំបន់ទេសចរណ៍នីមួយៗ ។

សមាមាត្រនៃការមកទស្សនាសរុប(ភ្ញៀវបរទេស ២០០៩)[២១]

| តំបន់គោលដៅ | % |
|---|---|
| ភ្នំពេញ | 42% |
| សៀម រាប | 41% |
| តំបន់ឆ្នេរ | 6% |
| តំបន់ឦសាន | 2% |
| តំបន់ផ្សេងៗ | 9% |

## តំបន់សៀមរាប និងបឹងទន្លេសាប

ទោះបីជាបរិវេណអង្គរដែលស្ថិតនៅខាងជើងបឹងទន្លេសាបនិងមានចំងាយមិនឆ្ងាយពីបឹងនេះក៏ដោយ ក៏នៅមានចំនួនទេសចរតិចតួចនៅឡើយទៅកំសាន្តនៅតំបន់បឹងនេះ។ តែទោះបីជាយ៉ាងនេះក៏ដោយ ក៏ដែនបបនីយជីវមណ្ឌលដែលកំណត់ដោយ UNESCO នេះបានបញ្ចូលជាទិសដៅសក្តានុពលដ៏សំខាន់សំរាប់ការអភិវឌ្ឍន៍ទេសចរណ៍នាពេលអនាគត ។

ដូចដែលកត់សំគាល់ពីមុនៗ ការផ្តល់សេវានៅក្នុងវិស័យទេសចរណ៍ត្រូវបានគេចាត់ទុកថាខ្វះនូវជម្រើសនិងគុណភាព។ នេះជាការពិត ជាពិសេសក្រៅពីតំបន់ទេសចរណ៍ដែលមានស្រាប់នៅសៀមរាប និងភ្នំពេញ ។ ទោះបីជាតំលៃពលកម្មទាបនៅកម្ពុជាក៏ដោយក៏កង្វះខាតត្រូវបានបង្ហាញអោយឃើញតាមរយៈការចំណាយខ្ពស់នៃការធ្វើដំណើរជាក្រុម។ ក្រុមហ៊ុនដែលអាចផ្តល់សេវាគុណភាពខ្ពស់សង្ឃឹមមានកំណើនល្អប្រសើរ និងអាចមានសក្តានុពលខ្ពស់សំរាប់ការវិនិយោគថ្មី ។ ទាំងនេះរួមទាំងសណ្ឋាគារលំដាប់អន្តរជាតិ ភោជនីយដ្ឋាន ក្រុមហ៊ុនទេសចរណ៍ និង មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ។

## ភ្នំពេញ

សេដ្ឋកិច្ចកំពុងរីកលូតលាស់របស់កម្ពុជាកំពុងទាក់ទាញនូវការចាប់អារម្មណ៍វិនិយោគយ៉ាងខ្លាំងលើគ្រប់វិស័យ ហើយនេះជំរុញអោយមានការវិនិយោគលើការធ្វើដំណើរ និងទេសចរណ៍ ។ របាយការណ៍ក្រុមប្រឹក្សាដំណើរកំសាន្តនិងទេសចរណ៍ពិភពលោកបានចាត់ចំណាត់ថ្នាក់ប្រទេសកម្ពុជាលេខរៀងទី១៧ ក្នុងចំណោមប្រទេស១៣១ ចំពោះការព្យាករណ៍កំណើននៃទេសចរបែបជំនួញនៅឆ្នាំ២០១០។ ចំនួនទេសចរបែបជំនួញដែលមកដល់ចំណតអាកាសយានដ្ឋានភ្នំពេញ គឺប្រហែល១៦% នៃដំណើរមកដល់ទាំងអស់ ដែលលើសពីកំរិតមធ្យមយ៉ាងខ្លាំង សំរាប់កម្ពុជាដែលមានចំនួន ៦,៧% ។

មជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៌កោះពេជ្រ ដែលគ្រប់គ្រងដោយក្រុមហ៊ុនវិនិយោគបរទេសគ្របដណ្តប់លើផ្ទៃដី១០០ហិកតា។ គម្រោងមានផែនការពង្រីកបន្ថែមដើម្បីកសាងអគារកំពស់៣៣៣ម ទីលានវប្បធម៌ មជ្ឈមណ្ឌលជំនួញ និងមជ្ឈមណ្ឌលសិល្បៈនៅឆ្នាំ ២០១៦។ កោះពេជ្រគឺជាមជ្ឈមណ្ឌលតាំងពិព័រណ៌អន្តរជាតិជាប្រចាំរួមទាំង វេទិកាទេសចរណ៍អាស៊ានដែលបានរៀបចំកាលពីខែមករា ២០១១។ នៅឆ្នាំ២០១០ សណ្ឋាគារណាហ្គាវើលដែលនៅក្បែរនោះ បានទទួលនូវរង្វាន់សណ្ឋាគារធុរកិច្ចប្រចាំឆ្នាំនៅឯព្រឹត្តិការណ៍តាំងពិពរណ៌អំពីការធ្វើដំណើរទេសចរណ៍អន្តរជាតិ នៅទីក្រុងហូជីមិញ និងជាទីកន្លែងដែលនិយមសំរាប់ព្រឹត្តិការណ៍ការប្រជុំសន្និសីទ និងតាំងពិព័រណ៌ នៅភ្នំពេញ។

ការវិនិយោគបន្ថែមនៅក្នុងវិស័យទាំងនេះនឹងត្រូវការជាចាំបាច់ដើម្បីបន្តជំហានការអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់ប្រទេស ។

## តំបន់ឆ្នេរ

តំបន់ឆ្នេរភាគនិរតីនៃប្រទេសកម្ពុជាទទួលបាន ៦%នៃដំណើរទេសចរណ៍អន្តរជាតិទាំងអស់នៅក្នុងឆ្នាំ ២០០៩ ។ តែ ទោះជាយ៉ាងណាក្តី ការអភិវឌ្ឍន៍ទេសចរណ៍តំបន់ឆ្នេរគឺជាកត្តាគន្លឹះនៃយុទ្ធសាស្ត្ររបស់រដ្ឋាភិបាល ដើម្បីលើកទឹកចិត្តភ្ញៀវទេសចរឲ្យស្នាក់នៅយូរ និងទាក់ទាញឲ្យធ្វើដំណើរទៅកន្លែងផ្សេងទៀត

ក្រៅពីតំបន់អង្គរវត្ត ដែលជាទីកន្លែងទាក់ទាញធំបំផុត ។

រដ្ឋាភិបាលបានកសាងអាកាសយានដ្ឋានអន្តរជាតិនៅខេត្តព្រះសីហនុ ដែលជាទីក្រុងធំបំផុតនៅក្នុងតំបន់ឆ្នេរដែលអាចជាទីផ្សារសក្តានុពលរីកលូតលាស់ដូចជា សិង្ហបូរី និងហុងកុង មានការតភ្ជាប់យ៉ាងងាយ ។ លើសពីនេះទៅទៀត តំបន់នេះត្រូវបានគេចាត់ទុកនៅក្នុងយុទ្ធសាស្រ្តអភិវឌ្ឍន៏ទេសចរណ៍មហាអនុតំបន់ទន្លេមេគង្គជាច្រករបៀងឆ្នេរសមុទ្រទេសចរណ៍ភាគខាងត្បូង និងជាផ្លូវឆ្លងកាត់ងាយស្រួលរវាងប្រទេសថៃភាគខាងលិចកម្ពុជា ជាមួយនឹងប្រទេសវៀតណាមភាគខាងត្បូង ។

ចាប់តាំងពីឆ្នាំ ២០០៨ តំបន់នេះត្រូវបានគេចាប់អារម្មណ៍លើការវិនិយោគបរទេសនិងផ្នែកឯកជនក្នុងស្រុកខ្លាំងផងដែរ។ គម្រោងអភិវឌ្ឍន៍ធំៗកំពុងដំណើរការយ៉ាងសកម្មដូចជា ឧទ្យានជាតិរាម ព្រមទាំងកោះរុង កោះសង្ឃា និងកោះដទៃទៀតដែលស្ថិតនៅមិនឆ្ងាយពីឆ្នេរសមុទ្រ ។

ដោយទទួលនូវនាវាទេសចរណ៍កំសាន្តដំបូងរបស់ខ្លួននៅខែធ្នូ ឆ្នាំ ២០០៨ កំពង់ផែអន្តរជាតិព្រះសីហនុបានទទួលនាវាទេសចរណ៍ចំនួន ២៦នៅឆ្នាំ ២០០៩ ដែលបង្ហាញពីសក្តានុពលរីកលូតលាស់យ៉ាងឆាប់រហ័សនាពេលអនាគត ។

ទោះបីមានប្រជាប្រិយខ្លាំងផ្នែកទេសចរណ៍តំបន់ឆ្នេក៏ដោយក៏តំបន់ប៉ែកនិរតីនេះមានតំបន់ទេសចរណ៍ធម្មជាតិជាច្រើនទៀត[២២]

| កំពត | កែប | កោះកុង | ព្រះសីហនុ |
|---|---|---|---|
| • ទឹកឈូ<br>• ឧទ្យានជាតិបូកគោ<br>• រូងភ្នំឈ្មោក | • កោះទន្សាយ<br>• ឆ្នេរសមុទ្រអង់កេង<br>• ព្រៃអូកាសា | • ភ្នំក្រវាញ<br>• ដែនជម្រកសត្វព្រៃឱរ៉ាល់<br>• ភ្នំព្រះ | • ឧទ្យានជាតិរាម<br>• កោះរុង<br>• ក្បាលឆាយ |

ទីតាំងតំបន់មានអំណោយផលហើយការវិនិយោគទុនលើហេដ្ឋារចនាសម្ព័ន្ធទាំងផ្នែកឯកជន និងសាធារណៈនឹងចូលរួមយ៉ាងសកម្មក្នុងការលើកកម្ពស់ចំនួនទេសចរថែមទៀត។ ជាងនេះទៅទៀតការអភិវឌ្ឍន៏ថ្មីៗជាច្រើនដែលផ្តោតលើទីផ្សារលំដាប់ខ្ពស់ៗត្រូវបង្កើនតម្រូវការសំរាប់សកម្មភាពទេចរណ៏និងសេវាកម្មដែលមានគុណភាពល្អ។

## *តំបន់ឦសាន*

ភាគឦសានដែលមានខេត្តក្រចេះ មណ្ឌលគិរី រតនគិរី និងខេត្តស្ទឹងត្រែង ត្រូវបានចាត់ទុកជាតំបន់ដែលមានសម្រស់ធម្មជាតិស្រស់បំព្រង ។ តែទោះជាយ៉ាងនេះក៏ដោយ បច្ចុប្បន្នតំបន់ឦសានជាតំបន់ដែលមានការអភិវឌ្ឍន៍ទេសចរណ៍តិចតួចនៅឡើយដែលមានត្រឹមតែ២%ប៉ុណ្ណោះនៃការទស្សនាសរុបនៅក្នុងឆ្នាំ ២០០៩។

តែទោះយ៉ាងនេះក្តី តំបន់ឦសានដែលជាចំណុចសំខាន់នៃផែនការជាតិនិងផែនការតំបន់ជាគោលដៅដ៏សំខាន់បំផុតក្នុងការអភិវឌ្ឍន៍តំបន់ឲ្យទៅជាតំបន់គោលដៅទេសចរណ៍ដ៏មានប្រជាប្រិយភាព រួមទាំងតំបន់ស្ថិតនៅក្នុងតំបន់អភិវឌ្ឍន៍អាទិភាពបីនៃយុទ្ធសាស្រ្តទេសចរណ៍មហាអនុតំបន់ទន្លេមេគង្គ។ តំបន់ទាំងនេះគឺមាន តំបន់ត្រីកោណមរកត តំបន់ត្រីកោណអភិវឌ្ឍន៍បៃតង និងច្រករបៀងទន្លេមេគង្គ ។

តំបន់ដែលគួរកត់សំគាល់បំផុតនៅក្នុងតំបន់នេះមានបង្ហាញក្នុងតារាងដូចខាងក្រោម[២៣]

| ក្រចេះ | មណ្ឌលគិរី | រតនគិរី | ស្ទឹងត្រែង |
|---|---|---|---|
| • អន្លង់ត្រីផ្សោត | • ទឹកជ្រោះប៊ូស្រា<br>• ព្រៃទន្លេស្រែពពក | • យក្សឡោម<br>• ឧទ្យានជាតិវីរជ័យ<br>• ទឹកជ្រោះអូសេនឡៃ | • តំបន់រាំសា<br>• ទឹកជ្រោះប្លាណេត និង អន្លង់ត្រីផ្សោតអន្លង់ឈើទាល |

ការវិនិយោគ និងការទាក់ទាញធម្មជាតិទាំងនេះ នឹងជំរុញកំនើនចំនួនភ្ញៀវទេសចរនៅក្នុងតំបន់ ដែលផ្តល់តាមតំរូវការអតិថិជនសំរាប់ការអភិវឌ្ឍន៍ នៅក្នុងប្រភេទអាជីវកម្មផ្សេងៗ ។ ដោយមានការធ្លាក់ចុះ ភ្ញៀវទេសចរគួរអោយកត់សំគាល់បើប្រៀបធៀបទៅនឹងតំបន់ ដទៃទៀតនៃប្រទេសកម្ពុជា គេរំពឹងថា វានឹងមានសក្តានុពលខ្លាំងសំរាប់ ការរីកលូតលាស់រយៈពេលវែង។ អេកូទេសចរណ៍ដែលរួមមាន អេកូឡូដ៍ ផ្ទះស្នាក់នៅ សួនសត្វ ដំណើរទេសចរណ៍តាមដងទន្លេ និងសកម្មភាពទេសចរណ៍ផ្សេងៗទៀត ផ្តល់ផលប្រយោជន៍ជាច្រើនដល់សម្បត្តិធម្មជាតិ ។

## ដៃគូអភិវឌ្ឍន៍នៅក្នុងវិស័យទេសចរណ៍

ដៃគូអភិវឌ្ឍន៍មួយចំនួនកំពុងជួយអភិវឌ្ឍន៍ទេសចរណ៍:

គម្រោងពង្រឹងសហគ្រាសខ្នាតតូចបំផុត ខ្នាតតូច និងខ្នាតមធ្យម (MSME) ឧបត្ថម្ភដោយ USAID បានជួយសម្របសម្រួលជំនួយបច្ចេកទេសនិងអាជីវកម្ម ដល់សហគ្រាសខ្នាតតូចបំផុត ខ្នាតតូច និងខ្នាតមធ្យមនៅតំបន់ជនបទប្រទេសកម្ពុជា ។ នៅក្នុងវិស័យទេសចរណ៍ គម្រោង MSME បានធ្វើការដើម្បីបង្កើត ក្រុមប្រឹក្សាភិបាលសិក្សាស្រាវជ្រាវទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍កម្ពុជា ដែលនឹងជំរុញអោយកម្ពុជាក្លាយជាតំបន់គោលដៅទេសចរណ៍លេចធ្លោមួយក្នុងតំបន់ ។

គម្រោងMSME ក៏បានផ្តោតការយកចិត្តទុកដាក់លើការសម្របសម្រួលជំនួយបច្ចេកទេសដល់ខ្សែសង្វាក់អាជីវកម្មប្រាំបី: វារីវប្បកម្ម ឥត-គ្រឿង ទឹកស្អាត និងបង្គន់អនាម័យ ការអភិវឌ្ឍន៍ជំនាញដល់ឧស្សាហកម្មកាត់ដេរ ទឹកឃ្មុំ ជ័រទឹក អេកូទេសចរណ៍ និងផ្លែឈើមានគុណភាពខ្ពស់ ។

**ការិយាល័យសម្របសម្រួលទេសចរណ៍មេគង្គ** គឺត្រូវបង្កើតឡើងដែលទទួលជំនួយតាមយុទ្ធសាស្រ្តទេសចរណ៍មហាអនុតំបន់មេគង្គដើម្បីសម្របសម្រួលគម្រោងអភិវឌ្ឍន៍នៅក្នុងតំបន់មេគង្គនិង ដើម្បីជំរុញវាឲ្យក្លាយទៅជាតំបន់គោលដៅទេសចរណ៍រួមមួយ។

**SNV**គឺជាអង្គការអភិវឌ្ឍន៍ហូឡង់ ដែលផ្តល់ការគាំទ្រដល់សហគ្រាសខ្នាតតូចបំផុត ខ្នាតតូច និង ខ្នាតមធ្យម នៅក្នុងវិស័យទេសចរណ៍។ ដោយសហការជាមួយនឹង ក្រសួងទេសចរណ៍ អង្គការទេសចរណ៍ពិភពលោក(UNWTO)និង អង្គការអភិវឌ្ឍន៍ហុល្លង់(SNV) បានអនុម័តគំរោងផ្លូវទស្សនាទន្លេមេគង្គ ដែលជាគម្រោង ផ្តោតទៅលើអេកូទេសចរណ៍នៅភាគឦសាននៃប្រទេសកម្ពុជា ។

**CCBEN** (បណ្តាញសហគមន៍ទេសចរណ៍ធម្មជាតិកម្ពុជា)គឺជាបណ្តាញមួយដែលមានសមាជិកជាង ៣០រួមមានសហគមន៍ អង្គការមិនមែនរដ្ឋាភិបាល ស្ថាប័នអប់រំ និងក្រុមហ៊ុនឯកជន ដែលធ្វើការយ៉ាងជិតស្និទ្ធផ្នែកអេកូទេសចរណ៍ ។

## ព្រឹត្តិការណ៍ថ្មីៗ

២០០៨ ប្រាសាទព្រះវិហារ បានទទួលការចុះបញ្ជីជាបេតិកភណ្ឌពិភពលោករបស់អង្គការយូនេស្កូ។

២០០៩ កាសែត*The Guardian* និង *The Observer* Travel Award បានចាត់ថ្នាក់ប្រទេសកម្ពុជាជាប្រទេសលំដាប់ទី២ដែលពេញនិយមរយៈពេលវែងផ្អែកតាមការស្ទង់មតិអ្នកអានជាង ១៩.០០០ នាក់ ។

២០០៩ ខេត្តកោះកុងនៃប្រទេសកម្ពុជាត្រូវបានជាប់នៅក្នុងចំណោមតំបន់កំពូលទាំង១០ នៅក្នុងសៀវភៅមគ្គុទេសក៍ទេសចរណ៍ *Lonely Planet* Best ២០១០ ។ សៀវភៅមគ្គុទេសក៍ទេសចរណ៍ បង្ហាញនូវប្រទេស តំបន់ និងទីក្រុងកំពូលទាំង១០ តាមការជ្រើសរើសដោយក្រុមការងារពិភពលោករបស់*LonelyPlanet* ។

២០១០ អង្គរវត្ត ត្រូវបានបោះឆ្នោតជារមណីយដ្ឋានយូនេស្កូដែលពេញនិយមបំផុតលំដាប់ទី១ ពិភពលោក ។ ការស្ទង់មតិធ្វើឡើងដោយ Trip

Advisor.com ដោយសហការជាមួយនឹង យូនេស្កូ ដែលមានមនុស្ស ២៥០.០០០នាក់បានបោះឆ្នោត[២៤] ។

២០១០ រាជរដ្ឋាភិបាលកម្ពុជា និងសាកលវិទ្យាល័យ the Sunshine Coast (អូស្ត្រាលី) បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងជាមួយគ្នា នៅសន្និសីទអេកូទេសចរណ៍អាស៊ីប៉ាស៊ីហ្វិកពិភពលោក ដើម្បីសហការអំពីការរៀបចំផែនការអេកូទេសចរណ៍ និងការបណ្តុះបណ្តាលវិជ្ជាជីវៈលើវិស័យទេសចរណ៍ ។

**ត្រូវការស្វែងយល់បន្ថែមទៀតទេ**?

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC)

www.cambodiainvestment.gov.kh

សភាពាណិជ្ជកម្មកម្ពុជា

www.ccc.org.kh

ក្រសួងទេសចរណ៍

http://www.mot.gov.kh/

អាជ្ញាធរអប្សរា

www.autoriteapsara.org

សមាគមភ្នាក់ងារទេសចរណ៍កម្ពុជា
**(CATA)**
www.catacambodia.com

បណ្តាញសហគមន៍ទេសចរណ៍ធម្មជាតិកម្ពុជា
**(CCBEN)**

www.ccben.org

# ស្ថិតិគន្លឹះ

## ព័ត៌មានសង្ខេបអំពីស្ថិតិទេសចរណ៍(២០០៩)[២៥]

| | |
|---|---|
| ចំនួនភ្ញៀវទេសចរ | ២,១៦ លាន |
| រយៈពេលស្នាក់នៅ | ៦,៤៥ ថ្ងៃ |
| ការចំណាយប្រចាំថ្ងៃ | ១១៧,២៥ដុល្លារ |
| ចំនួលក្នុងវិស័យទេសចរណ៍ | ១,៥៦១លានដុល្លារ |
| ទេសចរណ៍ចូលរួមក្នុងGDP | ១៤,៤៥% |

## ព័ត៌មានសង្ខេបអំពីកម្ពុជា[២៦]

| | |
|---|---|
| ទំហំផ្ទៃក្រឡា | ១៨១.០៣៥គម$^{២}$ |
| អាកាសធាតុ | ត្រូពិច |
| សីតុណ្ហភាពជាមធ្យម | ២៧$^{0}$C ឬ ៨0F |
| ចំនួនប្រជាជន | ១៣.៣៩៥.៦៨២(២០០៨) |
| អត្រាកំណើនប្រ/ជប្រចាំឆ្នាំ | ១,៥៤% |
| ភាសាផ្លូវការ | ខ្មែរ |
| ភាសាពាណិជ្ជកម្ម | ខ្មែរ និងអង់គ្លេស |
| សាសនា | ព្រះពុទ្ធ |
| ឆ្នេរសមុទ្រ | ៤៤០គម |

## អត្រាពន្ធកម្ពុជា[២៧]

| | | |
|---|---|---|
| ពន្ធលើប្រាក់ចំណេញ | ធម្មតា | ២០% |
| | លើកទឹកចិត្ត | 0% ឬ ៩% |
| ពន្ធអប្បបរមា | | ១%នៃផលរបរ |
| ពន្ធកាត់ទុក | | ១៥% |
| ប្រាក់ចំណូលពីការជួលអចលនវត្ថុ | | ១០% |
| ការបង់ប្រាក់ឲ្យអនិវាសនជន | | ១៤% |
| ពន្ធលើប្រាក់បៀវត្សរ៍(រៀលក្នុងមួយខែ) | | |
| 0 - ៥០០.000 | | 0% |
| ៥០០.00១-១.២៥០.000 | | ៥% |
| ១.២៥០.000 - ៨.៥០០.000 | | ១០% |
| ៨.៥០០.00១ - ១២.៥០០.000 | | ១៥% |
| ១២.៥០០.000+ | | ២០% |
| អនិវាសនជន | អត្រាថេរ | ២០% |
| ពន្ធបន្ថែមលើផលបន្ទាប់បន្សំ | | ២០% |
| ពន្ធបន្ថែមលើតំលៃ | | ១០% |
| | នាំចេញ | 0% |
| ពន្ធការផ្ទេរសិទ្ធិលើអចលនវត្ថុ | | ៤% |

## ទិន្នន័យម៉ាក្រូសេដ្ឋកិច្ចកម្ពុជា[២៨]

| កំណើន GDP(%) | ២០០៥ | ២០០៦ | ២០០៧ | ២០០៨ | ២០០៩ | ២០១០ |
|---|---|---|---|---|---|---|
| កំណើននាំចេញ | ១៣.៣ | ១០.8 | ១០.២ | ៦.៧ | -២ | ៤.៤ |
| លើទំនិញតែប៉ុណ្ណោះ | ១២.៤ | ២៦.៩ | ១០.៧ | ១៥.២ | -១៧ | ៥ |
| %នាំចេញលើតែទំនិញ | ៤៧% | ៥០% | ៤៧% | ៤៦% | ៣៩% | 0.៣៧ |
| វិនិយោគផ្ទាល់ពីបរទេស(FDI)លានដុល្លារ | ៣៧៥ | ៤៧៥ | ៨៦៦ | ៧៩៦ | ៥១៥ | ៧២៥ |
| FDI (% of GDP) | ៦% | ៦% | ១០% | ៨% | ៥% | 0.0៧ |

## ការចំណាយអាជីវកម្ម[៥]

| ដី | តំលៃលក់(គិតជាម$^{២}$) |
|---|---|
| ភ្នំពេញ ដីពាណិជ្ជកម្ម | ៨០០-៥០០០ដុល្លារ |
| សៀមរាប ដីពាណិជ្ជកម្ម | ៣០០-៥០០ ដុល្លារ |
| ខេត្តព្រះសីហនុ ដីពាណិជ្ជកម្ម | ៣០០-១០០០ដុល្លារ |
| ដីអភិវឌ្ឍន៍ (គ្រប់ខេត្ត/ក្រុង) | ៣០-១២០ ដុល្លារ |

| កន្លែងការិយាល័យ | ជួល/ខែ (គិតជាម$^{២}$) |
|---|---|
| តំបន់ល្អ | ១០-១៥ ដុល្លារ |
| តំបន់លំដាប់ទី២ | ៧-១០ ដុល្លារ |

| ពន្ធគយលើអគ្គិសនីនៅភ្នំពេញ ពាណិជ្ជកម្ម និងឧស្សាហកម្ម | ពន្ធគយ ដុល្លារ/kWh (មធ្យមភាគ ២០០៩) |
|---|---|
| តូច (<៦.៧៥០kWh) | 0,១៨៦៣ ដុល្លារ |
| មធ្យម( ≥៦.៧៥០kWh តែតិចជាង១៣.៥០០kWh) | 0,១៧៨៣ដុល្លារ |
| ធំ ( ≥១៣.៥០០kWh) | 0,១៧៤២ដុល្លារ |
| តផ្ទាល់ទៅនឹង MV | 0,១៧០៣ដុល្លារ |
| ការផ្គត់ផ្គង់ឧស្ម័នឧស្សាហកម្ម | 0,៣២ដុល្លារ/គក |

| តំលៃពលកម្ម | ប្រាក់ខែ(មួយខែ) |
|---|---|
| អ្នកចាត់ការជាន់ខ្ពស់ | ១០០០-១៥០០ដុល្លារ |
| អ្នកចាត់ការមធ្យម | ៥០០-១០០០ដុល្លារ |
| អ្នកចាត់ការចូលដំបូង | ២៤០-៤០០ ដុល្លារ |
| គណនេយ្យករ | ២៥០-៤០០ ដុល្លារ |
| លេខាធិការ | ១២០-១៥០ ដុល្លារ |
| ស្មៀនការិយាល័យ | ១០០-១២០ ដុល្លារ |
| អ្នកបើកបរ | ១០០-១២០ ដុល្លារ |
| អ្នកសំអាត | ៥០-៨០ ដុល្លារ |
| កម្មករ | ៥០-៨០ ដុល្លារ |
| ប្រាក់ឈ្នួលអប្បបរមាសំរាប់កម្មកររោងចក្រកាត់ដេរ | ៦០ ដុល្លារ |